**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

PHNOM PENH AUTONOMOUS PORT

**កំពង់ផែស្វយ័តភ្នំពេញ**

ថ្ងៃសុក្រ ៦ កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព. ស. ២៥៦៧

លេខ ១៧/២៣ ក. ស. ភ.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០២៣

# សេចក្ដីប្រកាសព័ត៌មាន

**កំពង់ផែស្វយ័តភ្នំពេញ** (**ក. ស. ភ.**) មានកិត្តិយសសូមជម្រាបជូនវិនិយោគិន និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា សម្រាប់ការិយបរិច្ឆេទសារពើពន្ធឆ្នាំ២០២១ និងឆ្នាំ២០២២ ក. ស. ភ. ទទួលបានការកោតសរសើរពីរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដោយ ក. ស. ភ. ជាសហគ្រាស ដែលបានចូលរួមចំណែកក្នុងការបំពេញកាតព្វកិច្ចបង់ពន្ធជារង្វៃក្នុងជូនរដ្ឋ និងជាប់ចំណាត់ថ្នាក់លេខ ៤២ (ឆ្នាំ២០២១) និងចំណាត់ថ្នាក់លេខ ៤៨ (ឆ្នាំ២០២២) ក្នុងចំណោមសហគ្រាសដែលបានបង់ពន្ធច្រើនជាងគេ និងទទួលបានអនុលោមភាពសារពើពន្ធប្រភេទ "មាស" ក្នុងឆ្នាំ២០២១ និងឆ្នាំ២០២២។

ក. ស. ភ. ពិតជាមានកិត្តយស និងមោទនភាពចំពោះស្នាដៃ ដែលសម្រេចបាននេះណាស់ ហើយ ក. ស. ភ. នឹងបន្តខិតខំប្រឹងប្រែងអភិវឌ្ឍអង្គភាពឱ្យកាន់តែរីកចម្រើនទៅមុខ និងបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវការបំពេញកាតព្វកិច្ចសារពើពន្ធតាមបទប្បញ្ញត្តិជាធរមាន ដើម្បីគាំទ្រដល់ការរីកចម្រើនលូតលាស់នៃសេដ្ឋកិច្ច និងសង្គមជាតិកម្ពុជា។

អាស្រ័យហេតុនេះ សូមវិនិយោគិន និងសាធារណជនទាំងអស់ទទួលជ្រាបជាព័ត៌មាន។

**កំពង់ផែស្វយ័តភ្នំពេញ**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

កំពង់ផែស្វយ័តភ្នំពេញ
ចូល
លេខ ៤៩៧/២៣ ក.ស.ភ.
ថ្ងៃទី ៥.៤.២៣ ម៉ោង ៩:៣០
បញ្ជូន

**ជូនចំពោះ**

**កំពង់ផែស្វយ័តភ្នំពេញ "ក.ស.ភ"**

PHNOM PENH AUTONOMOUS PORT "PPAP"

**លេខអត្តសញ្ញាណកម្មសារពើពន្ធ** L001-100044999

ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរដោយស្មោះអស់ពីដួងចិត្តជូនចំពោះ កំពង់ផែស្វយ័តភ្នំពេញ ដែលបានចូលរួមចំណែកក្នុងការបំពេញកាតព្វកិច្ចបង់ពន្ធដារផ្ទៃក្នុងជូនរដ្ឋ និងជាសហគ្រាសជាប់ចំណាត់ថ្នាក់លេខ ៤២ ក្នុងចំណោមសហគ្រាសដែលបានបង់ពន្ធច្រើនជាងគេ និងទទួលបានអនុលោមភាពសារពើពន្ធប្រភេទមាស ក្នុងឆ្នាំ២០២១។

ការបំពេញកាតព្វកិច្ចបង់ពន្ធរបស់កំពង់ផែស្វយ័តភ្នំពេញ គឺជាការចូលរួមចំណែកដែលមិនអាចខ្វះបានក្នុងឋានៈជាក្រុមហ៊ុនរបស់រដ្ឋដែលបានចូលរួមគាំទ្រដោយផ្ទាល់ និងជាកម្លាំងចលករសម្រាប់ការអភិវឌ្ឍនិងរីកលូតលាស់នៃសេដ្ឋកិច្ច និងសង្គមជាតិកម្ពុជា។

សូមជូនពរ ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់និងបុគ្គលិកទាំងអស់របស់ កំពង់ផែស្វយ័តភ្នំពេញ ទទួលបានជោគជ័យរាល់កិច្ចអាជីវកម្ម និងសមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃព្រហស្បតិ៍ ៧ រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២

**ហ៊ុន សែន**

កំពង់ផែស្វយ័តភ្នំពេញ
ចូល
លេខ ៤៩៤/២៣ ក.ស.ភ.
ថ្ងៃទី ១៥.៣.២៣ ម៉ោង ៨:៣០
ហត្ថលេខា

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**ជូនចំពោះ**
**កំពង់ផែស្វយ័តភ្នំពេញ "ក.ស.ភ"**
**PHNOM PENH AUTONOMOUS PORT "PPAP"**
**លេខអត្តសញ្ញាណកម្មសារពើពន្ធ** L001-100044999

ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរដោយស្មោះអស់ពីដួងចិត្តជូនចំពោះ កំពង់ផែស្វយ័តភ្នំពេញ ដែលបានចូលរួមចំណែកក្នុងការបំពេញកាតព្វកិច្ចបង់ពន្ធដារផ្ទៃក្នុងជូនរដ្ឋ និងជាសហគ្រាសជាប់ចំណាត់ថ្នាក់លេខ ៤៨ ក្នុងចំណោមសហគ្រាសដែលបានបង់ពន្ធច្រើនជាងគេ និងទទួលបានអនុលោមភាពសារពើពន្ធប្រភេទមាស ក្នុងឆ្នាំ២០២២។

ការបំពេញកាតព្វកិច្ចបង់ពន្ធរបស់កំពង់ផែស្វយ័តភ្នំពេញ គឺជាការចូលរួមចំណែកដែលមិនអាចខ្វះបានក្នុងឋានៈជាក្រុមហ៊ុនរបស់រដ្ឋដែលបានចូលរួមគាំទ្រដោយផ្ទាល់ និងជាកម្លាំងចលករសម្រាប់ការអភិវឌ្ឍនិងរីកលូតលាស់នៃសេដ្ឋកិច្ច និងសង្គមជាតិកម្ពុជា។

សូមជូនពរ ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់និងបុគ្គលិកទាំងអស់របស់ កំពង់ផែស្វយ័តភ្នំពេញ ទទួលបានជោគជ័យរាល់កិច្ចអាជីវកម្ម និងសមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃពុធ ១០ កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ✓

**ហ៊ុន សែន**